# លក្ខន្តិកៈ គោលនយោបាយ និងនីតិវិធី

**លក្ខន្តិកៈជាអ្វី?** (By-laws / Statute / Constitution)

ជាឯកសាររៀបរាប់ពីគោលបំណង រចនាសម្ព័ន្ធអង្គការ និងបទបញ្ញត្តិសំរាប់ប្រតិបត្តិការ។ តួនាទី និងអំណាចរបស់ក្រុមប្រឹក្សាភិបាល ត្រូវបានចែងក្នុងឯកសារ នេះផងដែរ។

**គោលនយោបាយជាអ្វី?** (Policy)

ជាច្បាប់លាយល័ក្សអក្សរ ដែលណែនាំដល់ការធ្វើសេចក្តីសំរេចចិត្ត ឬសកម្មភាពរបស់បុគ្គលិក និងអង្គការ។

**នីតិវិធីជាអ្វី?** (Procedure)

ជាជំហាន ឬដំណើរការសំរាប់ធ្វើកិច្ចការណាមួយ ឬសំរាប់អនុវត្តគោលនយោបាយមួយ។

**ប្រព័ន្ធជាអ្វី?** (System)

ជាបណ្តុំសមកម្មភាព ឬសមាសធាតុជាច្រើន ដែលមានការពាក់ព័ន្ធគ្នា និងដំណើរការជាមួយគ្នា។

**ឧទាហរណ៍: អង្គការមួយគួរមាន**

- លក្ខន្តិកៈ: ឬធម្មនុញ
- គោលនយោបាយបុគ្គលិក: អាចរួមបញ្ចូល កាំប្រាក់ គ/ន យេនឌ័រ គ/ន HIV/AIDS គ/ន សំរាប់ លើកកំពស់ជនជាតិដើមភាគតិច គ/បប្រឆាំងអំពើពុករលួយ ឬ គ/ប ទំនាស់ផលប្រយោជន៍ គ/បអភិវឌ្ឍន៍បុគ្គលិក ។ល។
- គោលនយោបាយហិរញ្ញវត្ថុ ឬក្បួនច្បាប់ហិរញ្ញវត្ថុ
- នីតិវិធីនានា ដូចជា នីតិវិធីបណ្តឹងតវ៉ាសំរាប់បុគ្គលិក នីតិវិធីជ្រើសរើសបុគ្គលិក នីតិវិធីរដ្ឋបាល ។ល។ (បញ្ជាក់: នីតិវិធីអាចត្រូវបានគេសរសេរជាមួយគោលនយោបាយ)។
- ប្រព័ន្ធនានា ដូចជា ប្រព័ន្ធវាយតំលៃបុគ្គលិក ប្រព័ន្ធត្រួតពិតនិត្យ និងវាយតំលៃ ប្រព័ន្ធហិរញ្ញវត្ថុ ប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា ។ល។

This learning article shared by Cambodian Learning Facilitators (www.camlefa.org).
This article can be copied, reproduced and used for any capacity development purpose, but source need to be clearly indicated.

## ហេតុអ្វីអង្គការចាំបាច់មានគោលនយោបាយ និងនីតិវិធី?

- ❒ ជាមូលដ្ឋានសំរាប់អង្គការ/បុគ្គលិកធ្វើសេចក្តីសំរេចចិត្ត ឬធ្វើសកម្មភាព
- ❒ សន្សំពេលវេលា ដោយចៀសវាងការគ្រប់គ្រងតាមករណីមួយៗ
- ❒ បញ្ជាក់ការរំពឹងទុក (រវាងអង្គការ និងបុគ្គលិក)
- ❒ លុបបំបាត់ភាពលំអៀង និងបក្សពួកនិយម
- ❒ លើកកំពស់សមភាព និងយុត្តិធម៌: ម្នាក់ៗគោរពច្បាប់តែមួយ
- ❒ ជាឧបករណ៍គ្រប់គ្រង ពេលអង្គការរីកលូតលាស់ (សូមមើលអត្ថបទ ស្តីពី ដំណាក់កាលអភិវឌ្ឍន៍អង្គការ ក្នុងគេហទំព័រនេះដែរ)។
- ❒ ជាផ្នែកមួយនៃអភិបាលកិច្ច: សំរាប់បង្ការ និង ដោះស្រាយទំនាស់ ឬបញ្ហារបស់បុគ្គលិក។

## ជំហានសំរាប់បង្កើតគោលនយោបាយ

- » បង្កើតលក្ខណ្ឌយោង សំរាប់ធ្វើការងារ
- » បង្កើតក្រុមការងារ
- » សិក្សា បទពិសោធន៍ និងទ្រឹស្តីល្អៗ
- » សិក្សាពីគោលនោយបាយអង្គការដទៃដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា
- » ពិគ្រោះយោបល់ជាមួយបុគ្គលិក និងអ្នកគ្រប់គ្រង (ជាក្រុម ឬជាបុគ្គល)
- » សរសេរពង្រាងលើកទី១
- » ដាក់ជូនក្រុមអ្នកគ្រប់គ្រង ដើម្បីទទួលយោបល់
- » កែសំរួល និងសរសេរពង្រាងចុងក្រោយ
- » ដាក់ជូនក្រុមប្រឹក្សាភិបាលដើម្បីអនុម័ត

*តើកន្លងមក អ្នកបានរៀបចំ*
*គោលនយោបាយរបស់អង្គការអ្នកដោយវិធីណា?*

This learning article shared by Cambodian Learning Facilitators (www.camlefa.org).
This article can be copied, reproduced and used for any capacity development purpose, but source need to be clearly indicated.